**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៤...ស.ព.ប

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស " ទិវាសេរីភាពសារព័ត៌មានសកលលោក " លើកទី១៦ នាថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧

បងប្អូនជនរួមជាតិជាទីគោរព ស្រឡាញ់ រាប់អាន !

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាទីស្នេហា !

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងសូមចូលរួមអបអរសាទរជាមួយបងប្អូនអ្នកសារព័ត៌មានជាតិ និងអ្នកសារព័ត៌មានអន្តរជាតិដែលកំពុងបំពេញការងារលើវិស័យសារព័ត៌មានទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាលើសកលលោកក្នុងឱកាសទិវាសេរីភាពសារព័ត៌មានសកលលោកដែលបានប្រារព្ធធ្វើឡើងនាថ្ងៃទី០៣ ខែឧសភាជារៀងរាល់ឆ្នាំ ហើយនេះជាខួបលើកទី១៦ នៃទិវាសេរីភាពសារព័ត៌មានសកលលោកក្នុងគោលបំណងលើកស្ទួយសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងធានាបាននូវគុណភាព សេរីភាពនៃសារព័ត៌មានដើម្បីចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សកលលោកប្រកបដោយចីរភាព។

ខួបលើកទី១៦នៃទិវាសេរីភាពសារព័ត៌មានសកលលោកឆ្នាំ២០១៧ បានផ្តោតលើប្រធានបទស្តីពីសារសំខាន់នៃការពង្រឹងសេរីភាព និងគុណភាពសារព័ត៌មាន ដើម្បីធានាដល់ការចូលរួមរបស់សារព័ត៌មានក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សកលលោកប្រកបដោយចីរភាព នេះគឺជាបំណងប្រាថ្នា និងជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការគោរព លើកកម្ពស់យ៉ាងហ្មត់ចត់នូវសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាមូលដ្ឋាន និងការកសាងគុណភាពព័ត៌មានក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ អាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅអភិបាលកិច្ចល្អដែលផ្តោតទៅលើវិស័យជាអទិភាពចម្បងគឺ ការប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ។

ការអនុវត្តយុទ្ធសាស្ត្រទាំងបីនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺការពង្រឹងគុណ

ភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈតាមរយៈការបង្កើតនិងដាក់ឲ្យអនុវត្តនូវស្តង់ដាសេវាសាធារណៈដោយផ្តោតលើសូចនាករគោលសំខាន់ៗគឺគុណភាពព័ត៌មាន ការទទួលយកព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាជាដើម ដែលទាមទារឲ្យរាជរដ្ឋាភិបាលកម្ពុជា ធានាឲ្យបាននូវសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ លំហូរព័ត៌មានដោយគុណភាព និងសេរីភាពនៃសារព័ត៌មានប្រកបដោយវិជ្ជាជីវៈនៅក្នុងក្របខណ្ឌប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលធានាឲ្យប្រជាពលរដ្ឋមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ ហើយច្បាប់ស្តីពីរបបសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា បានធានាឲ្យការបោះពុម្ពផ្សាយដោយគ្មានការត្រួតពិនិត្យជាមុន ព្រមទាំងបានផ្តល់សិទ្ធិដល់ជនបរទេសអាចកាន់កាប់សារព័ត៌មានជាភាសាខ្មែររហូតដល់ទៅ២០ភាគរយនៃចំនួនសារព័ត៌មានសរុប។

ជាមួយគ្នានេះដែរ ដើម្បីធានានូវការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នៅក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាល បានប្រគល់ភារកិច្ចឲ្យក្រសួងព័ត៌មានសហការជាមួយការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា អង្គការយូណេស្កូ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល ព្រមទាំងដៃគូពាក់ព័ន្ធនានា រៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឲ្យបានរួចរាល់នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភា ដើម្បីធានាការផ្តល់សិទ្ធិសេរីភាពជូនប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានពីស្ថាប័នរដ្ឋជាអតិបរមា ដែលជាកត្តាជំរុញឲ្យការអនុវត្តប្រជាធិបតេយនីយកម្មសង្គមកម្ពុជា របស់រាជរដ្ឋាភិបាលទទួលបានជោគជ័យដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកសារព័ត៌មានព្រមទាំងដៃគូពាក់ព័ន្ធផ្សេងទៀត។

ដោយមើលឃើញនូវភាពចាំបាច់ និងសារៈសំខាន់នៃការបញ្ចេញមតិនិងសេរីភាពសារព័ត៌មាន រាជរដ្ឋាភិបាលបានសម្រេចលុបចោលទោសជាប់ពន្ធនាគារនៃបទបរិហារកេរ្តិ៍ចេញពីក្រមព្រហ្មទណ្ឌ និងបានធានាថា មិនមានប្រជាពលរដ្ឋណាម្នាក់ត្រូវជាប់ពន្ធនាគារដោយសារការបញ្ចេញមតិឡើយ។

តាមរយៈនៃការបើកទូលាយនូវសិទ្ធិដល់ប្រជាពលរដ្ឋ និងសេរីភាពសារព័ត៌មាន រហូតមកដល់ពេលនេះ មានអង្គភាពសារព័ត៌មានជាតិ និងអង្គភាពសារព័ត៌មានបរទេស ទាំងមាននិន្នាការគាំទ្រគណបក្សប្រឆាំង ក៏ដូចជាសារព័ត៌មានដែលគាំទ្ររាជរដ្ឋាភិបាលដែលកំពុងធ្វើការផ្សព្វផ្សាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានចំនួន៥៣០អង្គភាព ក្នុងនោះមានកាសែតផ្សាយជាភាសាបរទេសចំនួន៤៣អង្គភាព ទស្សនាវដ្តីមានចំនួន៣០៦អង្គភាព ព្រឹត្តិបត្រព័ត៌មានចំនួន៤២អង្គភាព ការិយាល័យតំណាងទីភ្នាក់ងារសារព័ត៌មានបរទេស និងការិយាល័យតំណាងវិទ្យុ-ទូរទស្សន៍បរទេសប្រចាំការអចិន្ត្រៃយ៍នៅកម្ពុជា មានចំនួន២១ អង្គភាព ស្ថានីយវិទ្យុចំនួន២២១ ស្ថានីយទូរទស្សន៍ចំនួន២២ និងទូរទស្សន៍ផ្សាយបន្តមានចំនួន១១២ស្ថានីយ ទូរទស្សន៍ផ្កាយរណបតេជោ ធីវី មាន០១ស្ថានីយ ទូរទស្សន៍ឌីជីថល (Pay-TV)មានចំនួន០៤ស្ថានីយ និងទូរទស្សន៍អនឡាញមានចំនួន៥៨ អង្គភាព កំពុងដំណើរការធ្វើអាជីវកម្មនៅកម្ពុជា។

សមិទ្ធផលនៃការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយ ស្របតាមនិន្នាការរីកចម្រើននៃបច្ចេកវិទ្យាទំនើប

នាពេលបច្ចុប្បន្ន បានបង្ហាញឲ្យឃើញអំពីការបើកទូលាយនូវការគោរពសិទ្ធិបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន និងការគោរពសិទ្ធិមនុស្សស្របតាមគោលការណ៍ប្រជាធិបតេយ្យនៅកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមអរគុណ និងសូមវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏ចម្បងរបស់អ្នកសារព័ត៌មានជាតិ-អ្នកសារព័ត៌មានអន្តរជាតិ ពិធីករ-ពិធីការិនី ស្ថានីយវិទ្យុទូរទស្សន៍ដែលកំពុងបំរើការងារនៅក្នុងអង្គភាពសារព័ត៌មាននិងនៅតាមអង្គភាពប្រព័ន្ធផ្សព្វផ្សាយនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានប្រកបដោយវិជ្ជាជីវៈអំពីស្ថានភាពនយោបាយ ការអភិវឌ្ឍ និងសភាពការណ៍ពិតនៅកម្ពុជា ចាប់តាំងពីដំណាក់កាលប្រទេសជាតិមានសង្គ្រាម និងដំណាក់កាលស្វែងរកសន្តិភាពរហូតដល់ប្រទេសបានទទួលសុខសន្តិភាពពេញលេញនិងមានការអភិវឌ្ឍជូនប្រជាពលរដ្ឋ និងអន្តរជាតិ ឲ្យបានយល់ដឹងអំពីស្ថានភាពនយោបាយ សុខសន្តិភាព និងការអភិវឌ្ឍនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ អ្នកសារព័ត៌មាននិងពិធីករ-ពិធីការិនីស្ថានីយវិទ្យុ-ទូរទស្សន៍ពិតជាមានតួនាទីសំខាន់ណាស់ក្នុងការរួមចំណែកអប់រំប្រជាពលរដ្ឋឲ្យបានយល់ដឹងអំពីច្បាប់ សីលធម៌សង្គម វប្បធម៌ សេដ្ឋកិច្ច បរិស្ថាន សុខភាព អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សានៅក្នុងសង្គម ការប្រើប្រាស់គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ដែលជាបញ្ហាសំខាន់បំផុតដែលរាជរដ្ឋាភិបាលកំពុងផ្តោតយកចិត្តទុកដាក់។

នៅពេលដ៏ខ្លីខាងមុខនេះ នៅកម្ពុជានឹងមានការរៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់។ នៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជនមានតួនាទីសំខាន់ណាស់ក្នុងការផ្សព្វផ្សាយព័ត៌មាន ដែលតម្រូវឲ្យអ្នកសារព័ត៌មានប្រកាន់យកភាពអព្យាក្រឹត្យនិងគោរពច្បាប់ ក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីធានាឲ្យបរិយាកាសនយោបាយ និងដំណើរការនៃការបោះឆ្នោតនៅកម្ពុជា ប្រកបដោយភាពត្រឹមត្រូវ សេរី យុត្តិធម៌ ហើយលទ្ធផលនៃការបោះឆ្នោតអាចទទួលយកបាន ដែលឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋ ដើម្បីធានាបាននូវសន្តិសុខ សុវត្ថិភាព និងការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព។

ជាលទ្ធផលនៅក្នុងការចូលរួមចំណែកពីអ្នកសារព័ត៌មាននាពេលកន្លងមក គឺរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដែលកម្ពុជាបានចូលរួមអនុវត្តដូចជាកាត់បន្ថយភាពក្រីក្រសមភាពយេនឌ័រ ហេដ្ឋារចនាសម្ព័ន្ធ ជាមពលកកើតឡើងវិញនិងតម្លៃសមរម្យ ការអប់រំគោលប្រកបដោយគុណភាព និងមានគោលដៅចំនួន៦ដែលបានសម្រេចរួចរាល់មុនកាលបរិច្ឆេទកំណត់គឺ ការកាត់បន្ថយអត្រាមរណៈភាពកុមារ ការលើកកម្ពស់សុខភាពមាតា ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ ជំងឺរបេង និងបង្កើនភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ និងបានដំណើរការបោះឆ្នោតប្រកបដោយភាពត្រឹមត្រូវ សេរី និងយុត្តិធម៌ទទួលបានជោគជ័យនាពេលកន្លងៗមក។

ក្នុងការចូលរួមកសាងសន្តិភាព អ្នកសារព័ត៌មាន មានតួនាទីសំខាន់ក្នុងការសម្របសម្រួលផ្នែកនយោបាយ។ នៅពេលនយោបាយក្នុងប្រទេសមានសភាពតានតឹងនិងមានជម្លោះជាមួយប្រទេសជិតខាង សារព័ត៌មានដើរតួនាទីជាអ្នកសម្របសម្រួល តាមរយៈការសរសេរអត្ថបទរបស់ខ្លួន ដោយប្រកាន់ខ្ជាប់តាម

ក្រមសីលធម៌ វិជ្ជាជីវៈ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានការទទួលខុសត្រូវខ្ពស់ មិនបំប៉ោងព័ត៌មាន ដែលធ្វើឲ្យសភាពការណ៍នយោបាយឡើងកំដៅ ក្នុងន័យនេះ សារព័ត៌មានប្រៀបដូចទឹកដែលធ្វើឲ្យកំដៅ សភាពការណ៍នយោបាយវិលមករកភាពត្រជាក់ឡើងវិញៗ ទាំងនេះ បានឆ្លុះបញ្ចាំងអំពីតួនាទីដ៏សំខាន់ របស់សារព័ត៌មានក្នុងការចូលរួមកសាងសុខសន្តិភាព ស្ថេរភាពនយោបាយ ការអភិវឌ្ឍប្រទេសជាតិដោយ ការផ្តល់ព័ត៌មានប្រកបដោយការជឿទុកចិត្ត និងការទទួលខុសត្រូវទៅលើអាជីពរបស់ខ្លួនៗ

មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវដល់អ្នកសារព័ត៌មានជាតិ-អន្តរជាតិ ពិធីករ ពិធីការិនីស្ថានីយវិទ្យុ-ទូរទស្សន៍ទាំងអស់ ដែលកំពុងបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមយកចិត្តទុកដាក់អនុវត្ត ឲ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ ជៀសវាងការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុង ហើយឆ្លុះបញ្ចាំង សភាពការណ៍ទាំងមូល ដោយពុំបានគិតអំពីក្បួនខ្នាតក្រឹត្យក្រមនៃការសរសេរព័ត៌មាន និងការផ្សព្វផ្សាយ ព័ត៌មានមិនពិត បំប៉ោងសភាពការណ៍ ធ្វើឲ្យបាត់បង់តម្លៃព័ត៌មាន និងរុញច្រានស្ថានភាពនយោបាយ ប្រទេសធ្លាក់ក្នុងស្ថានភាពវឹកវរ អស្ថិរភាពនយោបាយ និងមានជម្លោះប្រដាប់អាវុធ និងសូមឲ្យអ្នកសារ-ព័ត៌មានចូលរួមផ្សព្វផ្សាយព័ត៌មានដែលមានសារសំខាន់ ពាក់ព័ន្ធនឹងការអប់រំអំពីបញ្ហាគ្រឿងញៀន ការអប់រំគ្រោះថ្នាក់ចរាចរណ៍ បញ្ហាសុខភាព ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ ប្រឆាំង និងលុបបំបាត់បញ្ហាគ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ ដែលបង្កឲ្យមានការបាត់បង់ជីវិតរបស់ប្រជាពលរដ្ឋ របស់យើងជារៀងរាល់ថ្ងៃនិងបានបំផ្លាញដល់សុខភាព ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋនិងជាពិសេសអនាគត របស់យុវជនរបស់យើងដែលជាទំពាំងស្នងឫស្សី ដែលរាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់បណ្តុះ បណ្តាលឲ្យក្លាយទៅជាពលរដ្ឋល្អសម្រាប់កសាងប្រទេសជាតិទៅថ្ងៃអនាគតនិងសូមឲ្យអ្នកសារព័ត៌មាន ចូលរួមក្នុងការពង្រឹងគុណភាពព័ត៌មានដើម្បីធានាដល់ការចូលរួមរបស់សារព័ត៌មានក្នុងការសម្រេច គោលដៅអភិវឌ្ឍន៍សកលលោកប្រកបដោយចីរភាព ។

ទីបញ្ចប់ ខ្ញុំសូមជូនពរបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទទួលជោគជ័យក្នុងការបំពេញ តួនាទីភារកិច្ចរបស់ខ្លួន និងសូមប្រកបនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយៗ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**